# ដំណើររឿងរបស់នីខូឡាស និង អ៊ែលីណា

នីខូឡាស និង អ៊ែលីណា បានរស់នៅក្នុងជីវិតអាពាហ៍ពិពាហ៍យ៉ាងសប្បាយរីករាយអស់រយៈពេល ១០ ឆ្នាំ ហើយមានកូនបីនាក់ ។ ពួកគេទាំងពីរនាក់ចង់ឲ្យគ្រួសាររបស់ពួកគេស្ថាបនាឡើងនៅលើគ្រឹះនៃព្រះយេស៊ូវគ្រីស្ទ និងដំណឹងល្អរបស់ទ្រង់ ហើយពួកគេម្នាក់ៗខិតខំបំពេញនូវទំនួលខុសត្រូវគ្រួសាររបស់ពួកគេដែលបានតែងតាំងឡើងដោយព្រះ ។

ក៏ដូចជាគូស្វាមីភរិយាដទៃទៀតដែរ នីខូឡាស និងអ៊ែលីណា មានការខ្វែងគំនិតគ្នា ។ ជាធម្មតា ការខ្វែងគំនិតរបស់ពួកគេគឺអំពីលុយ ។ នីខូឡាស ធ្វើការពេញម៉ោងនៅខាងក្រៅផ្ទះ ។ អ៊ែលីណា មើលថែកូនៗរបស់ពួកគេ និងផ្ទះសម្បែងពេញម៉ោង ដែលជាការងារបន្ថែមពីលើការងារតូចៗម្ដងម្កាល ។ នីខូឡាស គិតថាតួនាទីរបស់គាត់ក្នុងការធ្វើជាអ្នកដឹកនាំនៅក្នុងផ្ទះ ក៏ដូចជាអ្នកដែលរកប្រាក់បានច្រើនជាង មានន័យថាគាត់គួរតែជាអ្នកសម្រេចចិត្តចុងក្រោយអំពីរបៀបដែលពួកគេចំណាយលុយ ។ អ៊ែលីណា មានអារម្មណ៍ថានាងគួរមានអំណាចច្រើនជាងនេះនៅក្នុងការសម្រេចចិត្តដែលទាក់ទងនឹងកូនៗ ដោយសារនាងនៅជាមួយពួកគេច្រើនជាង នីខូឡាស ។ កាលពីអតីតនៅពេលខ្លះ នាងបានចំណាយប្រាក់តាមចិត្តរបស់នាងដោយពុំប្រាប់ដល់ នីខូឡាស ឡើយ ។

នាពេលថ្មីៗនេះ នីខូឡាស និង អ៊ែលីណា បានពិភាក្សាអំពីការប្រើប្រាស់លុយដែលពួកគេបានសន្សំទុកខ្លះនោះ ។ នីខូឡាស ចង់យកលុយនោះទៅទិញឡានដែលធ្វើឲ្យគាត់ងាយស្រួលទៅធ្វើការ និងសម្រាប់ក្រុមគ្រួសារពួកគេទៅណាទៅណី ។ អ៊ែលីណា ចង់ប្រើលុយនោះនាំកូនទៅលេងសាច់ញាតិ និងបទពិសោធន៍សប្បាយៗជាមួយគ្នាពីមុនកូនៗកាន់តែធំ ។

នីខូឡាស និងអ៊ែលីណា បានថ្លឹងថ្លែងពីការខ្វែងគំនិតនេះ ប៉ុន្តែត្រូវតែធ្វើការសម្រេចចិត្ត ។

- តើអ្នកគិតថា អ្វីជាការប្រឈមដ៏ធំបំផុតដែលនីខូឡាស និងអ៊ែលីណាកំពុងជួបប្រទះ ក្នុងការសម្រេចចិត្តថាតើត្រូវចំណាយលុយលើអ្វី ?
- តើអ្នកគិតថា ពួកគេត្រូវយល់យ៉ាងណាខ្លះអំពីភាពជាដៃគូស្មើភាពគ្នា និងការធ្វើជាអ្នកដឹកនាំទាក់ទងនឹងការសម្រេចចិត្តសម្រាប់គ្រួសាររបស់ពួកគេ ? ( សូមមើល ផ្នែកទី ៣ នៃឯកសាររៀបចំ ) ។
- ប្រសិនបើអ្នកជា នីខូឡាស ឬ អ៊ែលីណា តើអ្នកនឹងដោះស្រាយជាមួយស្វាមី ឬភរិយារបស់អ្នកយ៉ាងដូចម្ដេច ដើម្បីប្រឹក្សាគ្នាអំពីការសម្រេចចិត្តនេះតាមរបៀបដូចជាព្រះគ្រីស្ទ ?

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០២២ by Intellectual Reserve, Inc. All rights reserved.